**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៨)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2012, 14:52
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យធ្វើសវនាការជាសាធារណៈ លើបណ្តឹងសាទុក្ខផ្សេងៗប្រឆាំងនឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង ០០២/០១ ឬ សំណើម្យ៉ាងទៀតសុំដាក់ចម្លើយតបរួមទៅនឹងចម្លើយតបទាំងបីរបស់មេធាវីការពារក្តី**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្តម
Michael G. KARNAVAS

**ចម្លងជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល៖**

**ចៅក្រម គង់ ស្រីម**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Agnieszka KLONOWIECKA-MILART**
**ចៅក្រម ម៉ុង មុនីចរិយា**

០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៨)

**ចៅក្រម Chandra Nihal JAYASINGHE**

**ចៅក្រម យ៉ា ណារិន**

**ចៅក្រម Florence Ndepele Mwachande MUMBA**

**សហព្រះរាជអាជ្ញា៖**

ជា លាង

Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីរបស់ខ្លួន ("មេធាវីការពារក្តី") សូមឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើសវនាការជាសាធារណៈ លើបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង ០០២/០១ ឬសំណើម្យ៉ាងទៀតសុំដាក់ចម្លើយតបរួមទៅនឹងចម្លើយតបទាំងបីរបស់មេធាវីការពារក្តី ("សំណើ")[១]។ ចម្លើយតបនេះធ្វើឡើងជាការចាំបាច់ ដោយសារតែសំណើរបស់សហព្រះរាជអាជ្ញា មិនអាចទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។

១. អង្គជំនុំជម្រះតុលាការកំពូលពុំមានយុត្តាធិការក្នុងការស្តាប់សក្ខីកម្មលើសំណើផ្សេងដាច់ដោយឡែកដែលធ្វើឡើងដោយ ក.ស.ព នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនាពេលនេះទេ[២]។

២. ក.ស.ព គួរដាក់បញ្ចូលសំណើនេះជាផ្នែកមួយនៃបណ្តឹងសាទុក្ខរបស់ខ្លួន។

៣. ក.ស.ព បានដាក់សំណើនេះ ជាសារណាមួយដាច់ដោយឡែក ដើម្បីគេចពីការកំណត់ចំនួនទំព័រនៃបណ្តឹងសាទុក្ខ ដោយពុំចាំបាច់ដាក់សំណើសុំបន្ថែមចំនួនទំព័រផង[៣] ឬដោយសារតែ ក.ស.ព មិនបានដាក់បញ្ចូលសំណើនេះក្នុងបណ្តឹងសាទុក្ខផង។

៤. ដោយពិចារណាទៅលើចរិតលក្ខណៈ ដែលមិនអាចទទួលយកបានយ៉ាងច្បាស់ក្រឡែតនៃបណ្តឹងសាទុក្ខ និងដោយពិចារណាជាចាំបាច់ទៅលើភាពឆាប់រហ័ស និងការសន្សំសំចៃថវិការបស់តុលាការនោះ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សំណើនេះទទួលយកបានក៏ដោយ ក៏មេធាវីការពារក្តីយល់ថា អង្គជំនុំជម្រះពុំមានយុត្តិកម្មក្នុងការអនុញ្ញាតឱ្យមានសវនាការសួរដេញដោលផ្ទាល់មាត់ជាសាធារណៈ ដូចដែលបានស្នើសុំដោយ ក.ស.ព នោះទេ[៤]។

---

[១] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យធ្វើសវនាការជាសាធារណៈ លើបណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង ០០២/០១ ឬ សំណើម្យ៉ាងទៀតសុំដាក់ចម្លើយតបរួមទៅនឹងចម្លើយតបទាំង៣របស់មេធាវីការពារក្តី, ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២, ឯកសារលេខ E163/5/1/6។

[២] នៅដំណាក់កាលសវនាការ អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការតែចំពោះការស្តាប់សក្ខីកម្មទៅលើបណ្តឹងសាទុក្ខដែលបានដាក់អនុលោមតាមវិធាន ១០៤ ប៉ុណ្ណោះ។

[៣] សេចក្តីណែនាំអនុវត្ត ៥.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ចែងថា ឯកសារដាក់នៅអង្គជំនុំជម្រះតុលាការកំពូល មិនត្រូវលើកពី ៣០ ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ៦០ទំព័រជាភាសាខ្មែរ។

[៤] ក.ស.ព បានយល់ឃើញដូចគ្នា ទាក់ទិននឹងសវនាការសួរដេញដោលផ្ទាល់មាត់ជាសាធារណៈដែលមេធាវីការពារក្តីបានស្នើ។ *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំ

៥. អង្គជំនុំជម្រះតុលាការកំពូលមានព័ត៌មានទាំងអស់ដែលចាំបាច់នៅចំពោះមុខខ្លួនហើយ។

៦. ក.ស.ព ពុំបានលើកឡើងអ្វីបន្ថែមទៀតដើម្បីពន្យល់ពីការមិនយកចិត្តទុកដាក់ក្នុងការងាររបស់ខ្លួនក្នុងការខកខានមិនបានប្ដឹងសាទុក្ខទៅតាមពេលវេលាកំណត់នោះទេ ហើយខ្លួនក៏មិនអាចបង្ហាញឱ្យគេជឿបានថា ខ្លួនមានសិទ្ធិស្នើសុំដាក់បណ្ដឹងសាទុក្ខបន្ទាន់បន្សំនោះដែរ។

៧. ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលនៅតែទទួលយកសំណើរបស់ ក.ស.ព ដែលសុំឱ្យមានសវនាការសួរដេញដោលផ្ទាល់មាត់ជាសាធារណៈនោះ មេធាវីការពារក្ដីក៏ត្រូវទទួលបានឱកាសស្មើគ្នាដែរ ដើម្បីឆ្លើយតបទៅនឹងល្បិចកលធ្វើការទំនាក់ទំនងជាសាធារណៈដែលមានលក្ខណៈគឃ្លើនយ៉ាងច្បាស់ក្រឡែតរបស់ ក.ស.ព ដែលធ្វើឡើងដើម្បីទទួលបានលទ្ធផលដែលទទួលបានតាមរយៈរបៀបនយោបាយ។

**អាស្រ័យ** ទៅលើមូលហេតុទាំងអស់ដូចបានលើកឡើងនៅក្នុងចម្លើយតបនេះ មេធាវីការពារក្ដីស្នើសុំដោយគោរពទៅអង្គជំនុំជម្រះតុលាការកំពូលមេត្តា**បដិសេធ**សំណើនេះ។

យើងខ្ញុំសូមដាក់ចម្លើយតបនេះដោយគោរព។

| | |
|---|---|
| **អាង ឧត្តម** | Michael G. KARNAVAS |

សហមេធាវីការពារក្ដីលោក អៀង សារី

ចុះហត្ថលេខានៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា **ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២**

---

ជម្រះសាលាដំបូង ដែលតម្រូវឱ្យជនជាប់ចោទត្រូវមានវត្តមាន ដើម្បីស្ដាប់ការចោទប្រកាន់ និងសេចក្ដីសន្និដ្ឋានបើកការចោទប្រកាន់, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២, ឯកសារលេខ E130/4/2, កថាខណ្ឌ ១០។